LOLC គឺជាក្រុមហ៊ុនមួយដែលបង្កើតឡើងនៅក្នុងឆ្នាំ ១៩៨០ ជាមួយសាជីវកម្ម ORIX របស់ប្រទេសជប៉ុន និង IFC ត្រួសត្រាយសេវាភតិសន្យានៅប្រទេសស្រីលង្កា។ បច្ចុប្បន្នសេវាភតិសន្យានៅប្រទេសស្រីលង្ការួមមានតួអង្គចំនួន ៧០ ហើយឧស្សាហកម្មនេះ រួមចំណែក ២,៤% ដល់ផលិតផលសរុបក្នុងស្រុក។ នៅក្នុងរយៈពេល ២៧ ឆ្នាំនៃការស្រង់បទពិសោធន៍ LOLC បានធ្វើបដិវត្តសេដ្ឋកិច្ចដោយអភិវឌ្ឍ និង លើកស្ទួយជីវភាពនៃវិស័យសហគ្រាសធុនតូចនិងមធ្យម។ ទោះបីជាមានសង្គ្រាមក្តី ក៏សេដ្ឋកិច្ចត្រូវបានទ្រទ្រង់ដោយកំណើននៃវិស័យសហគ្រាសធុនតូចនិងមធ្យមដែរ។

ដោយបានបោះជំហានទៅមុខមួយជំហានរួចហើយ ពេលនេះការយកចិត្តទុកដាក់ គឺការលើកស្ទួយវិស័យមីក្រូហិរញ្ញវត្ថុកសិកម្មជនបទ ដែលគឺជាកម្រិតមូលដ្ឋាននៃសេដ្ឋកិច្ច។

# ផ្នែកនានា

LOLC ជាមួយនឹងតម្រូវការក្នុងស្រុកបានធ្វើឯកទេសកម្មលើផលិតផលនានាដូចជា

| បរិក្ខារសហគ្រាសធុនតូចនិងមធ្យម | បរិក្ខារមីក្រូហិរញ្ញវត្ថុ |
|---|---|
| ភតិសន្យា | ឥណទានកសិដ្ឋានផលិតទឹកដោះគោ |
| ឥណទាន | ឥណទានដាំដំណាំ |
| លទ្ធកម្មជួល | ឥណតានផ្ដើមអាជីវកម្ម |
| ទុនរកស៊ី និង ទំនិញមានអប្បហារ | ឥណទានជួយបង្កើតជំនាញ |
| ខ្ចីប្រាក់ដោយមានវត្ថុធានា | រទេះកង់បី |
| ការធានារ៉ាប់រង | ត្រាក់ទ័រប្រើដៃ |
| ប្រាក់សន្សំ និង ប្រាក់បញ្ញើ | រទេះកង់ពីរ |
| ការគ្រប់គ្រងរហ័ស | ហិរញ្ញប្បទានប្រព័ន្ធថាមពលព្រះអាទិត្យប្រើនៅផ្ទះ |

LOLC រំពឹងថានឹងមានវត្តមាននៅក្នុងតំបន់នេះជាមួយនឹងជំនាញឯកទេសទាំងនេះ

# គោលដៅនិងអនាគត

- កម្ពុជាគឺជាប្រទេសមួយដែល LOLC ចង់មានវត្តមានក្នុងរយៈពេលវែង និង ចង់ឃើញមានសក្តានុពលកាន់តែច្រើនថែមទៀតនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ក៏ដូចជាជួយឱ្យអតិថិជនមីក្រូហិរញ្ញវត្ថុឈានចូលទៅក្នុងវិស័យសហគ្រាសធុនតូចនិងមធ្យម ។
- ជាមួយជំនាញរបស់ LOLC ក្នុងវិស័យសហគ្រាសធុនតូចនិងមធ្យម គោលដៅគឺដើម្បីអភិវឌ្ឍនគម្រូអាជីវកម្មប្រកបដោយនិរន្តរភាពមួយនៅកម្ពុជា ។ តាមរយៈកិច្ចអភិវឌ្ឍន៍នេះ យើងអាចពង្រឹងផលិតផលមានស្រាប់ ទន្ទឹមគ្នានឹងការនាំមកនូវផលិតផលថ្មីៗទៀតជាច្រើន ដូចជាកសិដ្ឋានផលិតទឹកដោះគោជាដើម ហិរញ្ញប្បទានថាមពលកកើតថ្មី និង ហិរញ្ញប្បទានអចលនទ្រព្យ ។
- គោលដៅនាំមកនូវផលិតផលថ្មីជាច្រើដ៏ពិតប្រាកដដើម្បីជួយវិស័យមីក្រូហិរញ្ញវត្ថុនេះ មិនទាន់សម្រេចបាននៅឡើយទេ ដោយសារ LOLC ទើបតែបានមកកម្ពុជាក្នុងរយៈពេលខ្លី ។
- ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ LOLC រំពឹងថានឹងនាំមកនូវផលិតផលរបស់ខ្លួនជូនដល់កម្ពុជា និងជួយលើកស្ទួយជីវិតរបស់វិស័យមីក្រូហិរញ្ញវត្ថុជាមួយនឹងផលិតផលពិសេស ក៏ដូចជាជំយយអភិវឌ្ឍវិស័យសហគ្រាសធុនតូចនិងមធ្យមផងដែរ ។

# វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

- ការដាក់បញ្ចូលគ្នា / ការរួមចូលគ្នាផ្តល់នូវឥទ្ធិពលសាមគ្គីគ្នា
- ប្រការនេះនឹងបង្កើតនូវស្ថានភាពរួមគ្នាផ្តាច់មុខ/ភាពផ្តាច់មុខ ដែលនឹងគ្រប់គ្រងលើកសិករ

# ផ្លូវចេញ

- ក្រោយពេលអភិវឌ្ឍក្រុមហ៊ុនឡើងដល់កម្រិតធំ ផ្លូវចេញប្រសើរបំផុតនោះ គឺតាមរយៈការដាក់លក់នៅក្នុងទីផ្សារហ៊ុនដែលនៅក្នុងនោះ ប្រជាជនកម្ពុជានឹងបានទទួលផលប្រយោជន៍